-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១** .- ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ២.៣០០លានរៀល (ពីរពាន់បីរយលានរៀលគត់) ពីជំពូក១០ (បៀវត្ស និងប្រាក់បំណាច់ )មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២** .- ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់បើកយុទ្ធនាការជំរើនជន បរទេស ដែលកំពុងរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**អនុក្រឹត្យ លេខ ៥៧ អនក្រ.បក**

**ស្តីពី**

**ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការ**

**ដឹកនាំការងារនៃកម្មវិធីសិលា**

៙

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ ២០០១

## សំរេច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះជំនួសឱ្យអនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ។

**មាត្រា២ .-**

អនុក្រឹត្យនេះកំណត់បេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំរចនាសម្ព័ន្ធរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដើម្បីគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍បែបវិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ហៅថា " កម្មវិធីសិលា " ដោយមានការចូលរួមអនុវត្តពីគណៈកម្មាធិការអភិវឌ្ឍន៍ជនបទគ្រប់លំដាប់ថ្នាក់ ។

**មាត្រា៣ .-**

គោលដៅចំបងនៃកម្មវិធីសិលា គឺការរួមចំណែកកាត់បន្ថយភាពក្រីក្រនៅជនបទ និងពង្រឹងអភិបាលកិច្ចមូលដ្ឋាន តាមរយៈការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។ ដើម្បីសំរេចគោលដៅនេះ កម្មវិធីសិលាត្រូវ :-

១-រៀបចំយន្តការនិងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនានា ក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយចីរភាព ។

២-ផ្តល់ហិរញ្ញប្បទាន សំរាប់អនុវត្តកម្មវិធីវិនិយោគខេត្ត ដើម្បីឆ្លើយតបនឹងតំរូវការពិតប្រាកដរបស់មូលដ្ឋាន ។

៣-វាយតំលៃប្រសិទ្ធភាពនៃប្រព័ន្ធ វិមជ្ឈការ និងវិសហមជ្ឈការនានា ក្នុងការរួមចំណែកអនុវត្តន៍គោលដៅអភិវឌ្ឍន៍ប្រទេស និងចងក្រងបទពិសោធន៍ទាំងនេះ ដើម្បីផ្តល់ជូនដល់ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលសំរាប់រៀបចំគោលនយោបាយ និងលិខិតបទដ្ឋាននានា សំរាប់អនុវត្តគោលនយោបាយនេះ ។

៤-បណ្តុះបណ្តាលធនធានមនុស្ស សំរាប់អនុវត្តយន្តការ និងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខ័ណ្ឌនៃកម្មវិធីសិលា ។

**មាត្រា៤ .-**

សមាសភាពគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាមានដូចខាងក្រោម :

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣-រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៥-អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦-អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | សមាជិក |
| ៧-អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |
| ៨-អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៩-អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកែទំរង់រដ្ឋបាលសាធារណៈ | សមាជិក |
| ១០-អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍ | អគ្គលេខាធិការ |

ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាមានសិទ្ធិសំរេចបំពេញបន្ថែមសមាជិករបស់គណៈកម្មាធិការនេះ ដោយយោងតាមសំណូមពរការងារនៃកម្មវិធីសិលា ។

**មាត្រា៥ .-**

បង្កើតក្រុមការងារសំរាប់ជាវេទិកាក្នុងការសំរបសំរួល និងការពង្រឹងភាពជាដៃគូនៃកិច្ចសហប្រតិបត្តិការក្នុងកម្មវិធីសិលា រវាងរាជរដ្ឋាភិបាល និងសហគមន៍អ្នកផ្តល់ជំនួយ ។ ប្រធានគណៈកម្មា

ធិការដឹកនាំការងារនៃកម្មវិធីសិលា មានសិទ្ធិអញ្ជើញប្រធាន ឬតំណាងស្ថាប័ន និងអាជ្ញាធរដែនដី ព្រមទាំងភាគីផ្តល់ជំនួយនានាឱ្យ ចូលរួមប្រជុំក្នុងវេទិកានេះ ។

## ជំពូក ២

## ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា៦ ._**

គណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលាមានភារកិច្ច :

១-ទទួលខុសត្រូវក្នុងការគ្រប់គ្រងការអនុវត្តន៍កម្មវិធីសិលា ដើម្បីធានាតំលាភាពនិងគណនេយ្យភាពក្នុងការប្រើប្រាស់ប្រភពធនធានដែលមាន ។

២-ពិនិត្យនិងអនុម័តផែនការសិលា និងការវិភាជន៍ធនធានប្រចាំឆ្នាំ ។

៣-សំរបសំរួលការអនុវត្តន៍កម្មវិធីសិលា រវាងបណ្តាក្រសួងជាសមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងខេត្តអនុវត្តកម្មវិធីសិលា ។

៤-សំរួលការពិភាក្សាគោលនយោបាយ ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការខាងផ្នែកផែនការ ការងារហិរញ្ញវត្ថុ និងការគ្រប់គ្រងកិច្ចការអភិវឌ្ឍន៍មូលដ្ឋាន ក្របខ័ណ្ឌ នៃកម្មវិធីសិលា ។

៥-តាមដាន ត្រួតពិនិត្យ និងវាយតំលៃប្រសិទ្ធភាពនៃការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងខេត្តអនុវត្តកម្មវិធីសិលា និងចងក្រងបទពិសោធន៍ជូនរាជរដ្ឋាភិបាល សំរាប់ជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយជាតិ ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ។

៦-ពិនិត្យ និងសំរេចលើលទ្ធផលនៃសវនកម្ម ស្តីពីការគ្រប់គ្រងប្រព័ន្ធគណនេយ្យ ដើម្បីធានាឱ្យបានស្របនឹងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ។

៧-រាយការណ៍រៀងរាល់៦ខែ និងប្រចាំឆ្នាំ ស្តីពីការអនុវត្តន៍កម្មវិធីសិលា ជូនរាជរដ្ឋាភិបាល និងភាគីផ្តល់ជំនួយ ព្រមទាំងភាគីពាក់ព័ន្ធនានា ។

៨-បណ្តុះបណ្តាលធានធានមនុស្ស សំរាប់អនុវត្តការងារផែនការ ការងារហិរញ្ញវត្ថុ និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ។

៩-សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជួយរាជរដ្ឋាភិបាល ក្នុងការគៀងគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដល់កម្មវិធីសិលា ព្រមទាំងអាចចុះហត្ថលេខាជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលជំនួយដែលសហគមន៍អន្តរជាតិផ្តល់សំរាប់គាំទ្រកម្មវិធីសិលា ។

**មាត្រា៧ ៈ-**

គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា មានអគ្គលេខាធិការដ្ឋាន ដែលមានទីស្នាក់ការនៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

អគ្គលេខាធិការដ្ឋាននេះមានភារកិច្ចដូចខាងក្រោម :-

១-សំរបសំរួលដំណើរប្រព្រឹត្តទៅ របស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា មានជាអាទិ៍ ការរៀបចំផែនការការងារប្រចាំឆ្នាំ ចាត់ចែងនិងរៀបចំកិច្ចប្រជុំនិងរបៀបវារៈនៃអង្គប្រជុំគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

២-គ្រប់គ្រងកិច្ចប្រតិបត្តិការនៃកម្មវិធីសិលា ។

៣-រៀបចំរបាយការណ៍រៀងរាល់ ៦ខែ និងប្រចាំឆ្នាំ ស្តីពីការអនុវត្តន៍កម្មវិធីសិលា ។

៤-វាយតំលៃការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងក្របខ័ណ្ឌកម្មវិធីសិលា ព្រមទាំងផ្សព្វផ្សាយជូនបណ្តាភាគីពាក់ព័ន្ធ ។

៥-សំរបសំរួល និងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ដែលជាសមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា រវាងគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាជាមួយនឹងស្ថាប័នជាតិ ដទៃទៀត និងរវាងថ្នាក់ជាតិ និងថ្នាក់ខេត្តអនុវត្តកម្មវិធីសិលា ។

៦-ជួយរៀបចំ និងពិនិត្យសេចក្តីព្រាងកិច្ចព្រមព្រៀងហិរញ្ញប្បទានសំរាប់គាំទ្រកម្មវិធីសិលា រវាងសហគមន៍អ្នកផ្តល់ជំនួយ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៧-ចុះហត្ថលេខាលើលិខិតអញ្ជើញប្រជុំបច្ចេកទេសជាមួយក្រុមការងារតាមក្រសួង និងដឹកនាំកិច្ចប្រជុំនេះ ។

៨-គ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទានជាតិនិងអន្តរជាតិ ។

៩-គ្រប់គ្រង ប្រព័ន្ធគណនេយ្យនិងធ្វើសវនកម្មឱ្យបានសមស្របនឹងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ។

១០-បំពេញការងារផ្សេងៗទៀត តាមការប្រគល់សិទ្ធិរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលា ។

**មាត្រា ៨ ៈ-**

អគ្គលេខាធិការដ្ឋាននេះ ត្រូវបានដឹកនាំដោយអគ្គលេខាធិការនៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា អមដោយអគ្គលេខាធិការរង និងជំនួយការមួយចំនួនតាមការចាំបាច់ ។

**មាត្រា ៩ .-** អគ្គលេខាធិការដ្ឋាននៃកម្មវិធីសិលាចែកចេញជា ២ ផ្នែក :

១-ផ្នែកគ្រប់គ្រងកិច្ចប្រតិបត្តិការនៃកម្មវិធី

២-ផ្នែកត្រួតពិនិត្យ និងវាយតំលៃការអនុវត្តន៍គោលនយោបាយ

ផ្នែកទីមួយៗរបស់លេខាធិការដ្ឋានមានឋានៈស្មើនាយកដ្ឋាន នឹងបំពេញការងារជាជំនួយការរបស់អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។ តួនាទី និងភារកិច្ចរបស់ផ្នែកនីមួយៗចំណុះអគ្គលេខាធិការដ្ឋាន នឹងត្រូវកំណត់ដោយគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

**មាត្រា ១០ .-**

មន្ត្រីបំរើការងារក្នុងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធិសិលា គឺជាមន្ត្រីក្របខ័ណ្ឌដែលខ្ចីពីក្រសួង និងស្ថាប័ននានា ឬជាបុគ្គលិកដែលបំពេញការងារតាមកិច្ចសន្យា ។

**មាត្រា ១១ .-**

បង្កើតក្រុមការងារសិលានៅតាមក្រសួង ដើម្បីសំរបសំរួលនិងជួយការងារទាំងឡាយរបស់សមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធិសិលា ។

ក្រុមការងារសិលាតាមក្រសួងទាំងនេះ មានភារកិច្ចរួមដូចខាងក្រោម :-

១-ជាសមភាគីការងាររបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកម្មវិធិសិលា ។

២-រៀបចំផែនការការងាររបស់ក្រសួងដែលទាក់ទងទៅនឹងការអនុវត្តន៍កម្មវិធីសិលា ។

៣-ទំនាក់ទំនង និងគាំទ្រមន្ទីរខ្សែបណ្តោយរបស់ខ្លួននៅថ្នាក់ខេត្ត ឱ្យអនុវត្តកម្មវិធីសិលាប្រកបមានប្រសិទ្ធភាព និងដោះស្រាយរាល់បញ្ហានានា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

៤-ពិនិត្យផែនការ និងរបាយការណ៍អនុវត្ត ដែលទទួលបានពីមន្ទីរខ្សែបណ្តោយក្រសួង ។

៥-សំរបសំរួល និងសហការជាមួយក្រសួងផ្សេងៗ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នាក្នុងការអនុវត្តន៍កម្មវិធីសិលា ។

៦-ផ្សព្វផ្សាយលទ្ធផល និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការ តាមរយៈកម្មវិធីសិលានៅក្នុងក្រសួង និងផ្តល់អនុសាសន៍ទាំងឡាយដល់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា សំរាប់ពិនិត្យនិងពិចារណា ដើម្បីដាក់ជូនគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធិសិលាអនុម័ត ។

៧-ពិនិត្យតាមដានការអនុវត្តន៍កម្មវិធីសិលា តាមវិស័យរបស់ខ្លួននៅថ្នាក់ខេត្ត និងផ្តល់របាយការណ៍ជូនសមាជិកនៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

ភារកិច្ចដោយឡែកនៃក្រុមការងារសិលានៅតាមក្រសួងនីមួយៗ នឹងត្រូវកំណត់ដោយសមាជិកនៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលារបស់សាមីក្រសួង ដោយយោងតាមឯកសារកម្មវិធីសិលាឆ្នាំ ២០០១-២០០៥ ។

**មាត្រា ១២ .-**

គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង (គ.អ.ជ.ខ) ដែលមានអភិបាលខេត្ត-ក្រុង ជាប្រធាន ត្រូវទទួលខុសត្រូវ ក្នុងការគ្រប់គ្រងកម្មវិធីសិលា នៅថ្នាក់ខេត្ត ។ បន្ថែមលើភារកិច្ចដែលមានចែងក្នុងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ០២ សសរ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ត្រូវមានភារកិច្ចដូចខាងក្រោម :-

១-ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ខេត្ត ។

២-ពិនិត្យ និងផ្តល់ចំណារឯកភាពលើផែនការវិនិយោគសិលា ហើយស្នើមកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដើម្បីអនុម័ត ។

៣-អនុម័តការបែងចែកថវិកាវិភាជន៍មូលនិធិវិនិយោគសិលា ឱ្យស៊ីសង្វាក់នឹងយុទ្ធសាស្ត្រនៃកម្មវិធីសិលា ។

៤-ជ្រើសរើសតំបន់គោលដៅ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ និងលទ្ធភាពធនធានដែលមាន ។

៥-ជួយជំរុញ និងគាំទ្រកិច្ចសហការប្រកបដោយប្រសិទ្ធភាព រវាងស្ថាប័ននានារបស់រាជរដ្ឋាភិបាលផ្នែកឯកជន សង្គមស៊ីវិល និងភ្នាក់ងារអភិវឌ្ឍន៍ជាតិនានា ក្នុងការរៀបចំផែនការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ជនបទរបស់ខេត្ត ។

៦-ចាត់ចែង និងរិះរកវិធានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែលបានទទួលពីគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

៧-ពិនិត្យ និងឯកភាពលើរបាយការណ៍ ស្តីពីការអនុវត្តន៍ផែនការវិនិយោគសិលារបស់ខេត្ត ហើយផ្ញើមកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

**មាត្រា ១៣ .-**

ដើម្បីអនុវត្តភារកិច្ចដូចមានចែងក្នុងមាត្រា ១២ ខាងលើ គ.អ.ជ.ខ ត្រូវបង្កើតគណៈកម្មាធិការប្រតិបត្តិ ដែលមានសមាសភាព ភារកិច្ច និងរចនាសម្ព័ន្ធ តាមការណែនាំរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាថ្នាក់ជាតិ សំរាប់គ្រប់គ្រងការអនុវត្តន៍ផែនការវិនិយោគសិលាប្រចាំឆ្នាំរបស់ខេត្ត ។

**មាត្រា ១៤ .-**

គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក សំរាប់រាល់លិខិតផ្លូវការរបស់ខ្លួន ។

## ជំពូកទី ៣

## មូលនិធិ

**មាត្រា ១៥ .-**

ប្រភពនៃមូលនិធិសំរាប់អនុវត្តកម្មវិធីសិលា មានជាអាទិ៍ :-

១-ជំនួយឥតសំណង និងឥណទានពីអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី

២-ហិរញ្ញប្បទានពីថវិការដ្ឋ

៣-អំណោយពីសប្បុរសជននានា និងអង្គការក្រៅរដ្ឋាភិបាល ។

**មាត្រា ១៦ .-**

មូលនិធិដែលគៀងគរបានពីប្រភពដូចមានចែងក្នុងមាត្រា១៥ខាងលើ ត្រូវបានប្រើប្រាស់រាប់កិច្ចអភិវឌ្ឍន៍ជនបទតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ហៅថា " មូលនិធិអភិវឌ្ឍន៍វិមជ្ឈការ និងវិសហមជ្ឈការ " ហើយត្រូវបានគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំបទប្បញ្ញត្តិ និងនីតិវិធីសំរាប់កិច្ចដំណើរការនៃមូលនិធិនេះ ។

**មាត្រា ១៧ .-**

ក្នុងការគ្រប់គ្រងមូលនិធិនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ត្រូវអនុវត្តកិច្ចការដូចតទៅ :-

១-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគៀងគរធនធានក្នុងស្រុកនិងក្រៅប្រទេស សំរាប់កម្មវិធីសិលា ។

២-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតាមដានការអនុវត្តន៍កិច្ចព្រមព្រៀងហិរញ្ញប្បទាន ដែលបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ ព្រមទាំងរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្ញើជូនរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ តាមកាលកំណត់ដែលបានឯកភាពគ្នា ។

៣-ពិនិត្យតាមដានការផ្ទេរមូលនិធិអភិវឌ្ឍន៍វិមជ្ឈការ និងវិសហមជ្ឈការឱ្យទៅគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ដែលអនុវត្តកម្មវិធីសិលា ។

៤-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការធ្វើសវនកម្មគណនីរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៨ .-**

អនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ៤ និង អភិបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***